01248218

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 03 / 06 / 2016
ម៉ោង (Time/Heure) : 13:15
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

E319/47/2

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

## អង្គជំនុំជម្រះសាលាដំបូង

សាធារណៈ / Public

ថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០១៦

ជូនចំពោះ៖ ភាគីទាំងអស់នៃសំណុំរឿង 00២

ពី៖ ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

ចម្លងជូន៖ លោក/លោកស្រីចៅក្រម និង មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង

កម្មវត្ថុ៖ សេចក្តីសម្រេចលើសំណើសុំឲ្យទទួលយកកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចំនួន ៥ អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង (ឯកសារ E319/47)

១. អង្គជំនុំជម្រះបានទទួលសំណើរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង សុំឲ្យទទួលយកជាឯកសារភ័ស្តុតាងនូវកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចំនួន ៤៧ និងឯកសារមួយចំនួនដែលបានភ្ជាប់ជាឧបសម្ព័ន្ធ (ឯកសារ E319/47) ដែលកំណត់ហេតុនៃការស្តាប់ចម្លើយចំនួន ៥ ក្នុងចំណោមកំណត់ហេតុស្តាប់ចម្លើយទាំងនោះ ត្រូវបានកំណត់ប្រភេទយ៉ាងជាក់លាក់ថាជាចម្លើយដែលពាក់ព័ន្ធនឹងមន្ទីរសន្តិសុខ ស-២១។ ដោយយល់ឃើញថា បច្ចុប្បន្ននេះ អង្គជំនុំជម្រះកំពុងតែធ្វើសវនាការពិនិត្យភ័ស្តុតាងពាក់ព័ន្ធទៅនឹងមន្ទីរសន្តិសុខ ស-២១ នោះ អង្គជំនុំជម្រះបានកំណត់កាលបរិច្ឆេទធ្វើសវនាការស្តាប់ចម្លើយតបផ្ទាល់មាត់របស់ភាគីនានាលើសំណើនេះនៅថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០១៦។ ទោះបីជាមានការជំទាស់ទៅនឹងឯកសារផ្សេងៗទៀតក៏ដោយ ក៏មិនមានភាគីណាមួយជំទាស់ទៅនឹងការ

ទទួលយកឯកសារ E319/41.3.2, E319/41.3.1, E319/40.4.31, E319/46.3.2, E319/46.3.1 ដែលជាចម្លើយពីមុនៗរបស់សាក្សីដែលបានផ្តល់សក្ខីកម្មរួចហើយ ឬដែលត្រូវបានកំណត់ឱ្យមកផ្តល់សក្ខីកម្មលើអង្គហេតុនេះឡើយ។

២. អង្គជំនុំជម្រះសាលាដំបូងរម្លឹកឡើងវិញ អំពីការអនុវត្តរបស់ខ្លួនក្នុងការទទួលយកជាឯកសារភស្តុតាងនូវរាល់ចម្លើយពីមុនៗរបស់សាក្សី ដែលត្រូវមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំ-ជម្រះ អនុលោមតាមវិធាន ៨៧(៣) និង (៤) នៃវិធានផ្ទៃក្នុង (ឯកសារ E319/36/2 កថា-ខណ្ឌ ១៥, ឯកសារ E363/3 កថាខណ្ឌ ២៥)។ វាជាប្រយោជន៍ក្នុងការស្វែងរកការពិត ដែលអង្គជំនុំជម្រះ និងភាគីនានាអាចរកមើលបាននូវចម្លើយទាំងអស់របស់សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី ដែលនឹងត្រូវផ្តល់សក្ខីកម្មនៅក្នុងសំណុំរឿង ០០២។ លើសពីនេះទៀត ឯកសារទាំងនេះគួរត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ ដើម្បីអនុញ្ញាតឱ្យមានការវាយតម្លៃពេញលេញទៅលើសក្ខីកម្មរបស់ពួកគាត់។ ហេតុដូច្នេះ អង្គជំនុំជម្រះទទួលយកឯកសារទាំង ៥ ដែលបានបញ្ជាក់ជូនខាងលើ។

៣. អង្គជំនុំជម្រះរម្លឹកឡើងវិញថា នៅក្នុងសារអេឡិចត្រូនិកដែលអង្គជំនុំជម្រះបានផ្ញើជូនទៅភាគីនានា ដែលស្នើឱ្យភាគីឆ្លើយតបដោយផ្ទាល់មាត់ទៅនឹងឯកសារ E319/47 នោះ អង្គជំនុំ-ជម្រះបានកត់សម្គាល់ថា កំណត់ហេតុនៃការស្តាប់ចម្លើយចំនួន ៧ ក្នុងចំណោមកំណត់ហេតុនៃការស្តាប់ចម្លើយទាំងអស់នៅក្នុងឯកសារ E319/47 ពាក់ព័ន្ធទៅនឹងមន្ទីរសន្តិសុខ ស-២១។ បន្ទាប់ពីបានពិនិត្យមើលឡើងវិញបន្ថែមទៀតរួចមក កំណត់ហេតុនៃការស្តាប់ចម្លើយចំនួន ២ ក្នុងចំណោមកំណត់ហេតុនៃការស្តាប់ចម្លើយទាំងនេះ (ឯកសារ E319/47.2.19, ឯកសារ E319/47.2.20) ដែលមេធាវីការពារក្តី ខៀវ សំផន ជំទាស់នោះ មានព័ត៌មានតិចតួចប៉ុណ្ណោះពាក់ព័ន្ធទៅនឹងមន្ទីរសន្តិសុខ ស-២១។ ដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា វាមិនមែនជាបញ្ហាបន្ទាន់ដែលត្រូវពិចារណាអំពីការទទួលយកឯកសារទាំងនេះឡើយ។ អង្គជំនុំជម្រះនឹងពិចារណាលើឯកសារទាំងនេះ រួមជាមួយនឹងឯកសារដែលនៅសេសសល់ផ្សេងៗទៀតនៅក្នុងឯកសារ E319/47 នៅក្នុងពេលវេលាសមស្របខាងមុខ។